**មាត្រា ១២៥** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង និង គ្រប់អាណាប័ណ្ណដើមខ្សែ ឬ អាណាប័ណ្ណតាមការប្រទានសិទ្ធិ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ — នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា — ហត្ថលេខានិងត្រា

**នរោត្តម រណឫទ្ធិ** — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

## អនុក្រឹត្យលេខ ៨៦ អ.ន.ក្រ.បក

## ស្ដីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤– ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត. ១០៩៤– ៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមអនុសញ្ញា ស្ដីពីសិទ្ធិរបស់កុមារ ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បានចុះហត្ថលេខានៅថ្ងៃ ទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និង បានផ្ដល់សច្ចាប័ន នៅថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងសេចក្ដីថ្លែងការជាន់ខ្ពស់ជាសកល ដើម្បីកុមារដែលព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** បានឡាយព្រះហស្ថលេខា នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
- យោងលិខិតលេខ ១០១៥ សជណ.អវ. របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិ គ្រប់គ្រងកុមារកម្ពុជា

**សំរេច**

**មាត្រា ១** : បង្កើតក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ ហៅកាត់ « ក.ជ.ក.ក. » ក្នុងបំណង ធានាកិច្ចសហការ សំរបសំរួលឥសមស្របក្នុងការអនុវត្តន៍ ការតាមដានត្រួតពិនិត្យ និងវាយតំលៃលើគោលនយោបាយទាំងឡាយ និង កម្មវិធីដែលទាក់ទងទៅនឹងការ រស់រានមានជីវិត ការអភិវឌ្ឍន៍ ការការពារ ការលើកកំពស់សុខមាលភាព និង ការចូលរួមចំណែករបស់កុមារកម្ពុជា ។

**មាត្រា ២** : សមាសភាព « ក.ជ.ក.ក » រួមមាន ÷

| | | |
|---|---|---|
| ១– សម្ដេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ និង សម្ដេចនាយករដ្ឋមន្ត្រីទី ២ | | ជាសហប្រធានកិត្តិយស |
| ២– ឯកឧត្ដម រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន | | ជាប្រធាន |
| ៣– តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | ១ រូប | ជាអនុប្រធាន |
| ៤– តំណាងក្រសួងមហាផ្ទៃ | ១ រូប | ជាអនុប្រធាន |
| ៥– តំណាងក្រសួងអប់រំយុវជន និងកីឡា | ១ រូប | ជាអនុប្រធាន |

| | | |
|---|---|---|
| ៦– តំណាងក្រសួងសុខាភិបាល | ១ រូប | ជាអនុប្រធាន |
| ៧– តំណាងរដ្ឋលេខាធិការដ្ឋានកិច្ចការនារី | ១ រូប | ជាអនុប្រធាន |
| ៨– តំណាងរដ្ឋមន្ត្រីទទួលបន្ទុកមជ្ឈមណ្ឌលយុវនិតិសម្បទា | ១ រូប | ជាសមាជិក |
| ៩– តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ១ រូប | ជាសមាជិក |
| ១០– តំណាងក្រសួងផែនការ | ១ រូប | ជាសមាជិក |
| ១១– តំណាងក្រសួងយុត្តិធម៌ | ១ រូប | ជាសមាជិក |
| ១២– តំណាងក្រសួងពត៌មាន | ១ រូប | ជាសមាជិក |
| ១៣– តំណាងក្រសួងធម្មការ និង សាសនា | ១ រូប | ជាសមាជិក |
| ១៤– តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ១ រូប | ជាសមាជិក |
| ១៥– តំណាងកាកបាទក្រហមកម្ពុជា | ១ រូប | ជាសមាជិក |

**មាត្រា ៣** : តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និង អន្តរជាតិ តំណាង វិជ្ជាស្ថានស្រាវជ្រាវ ពាក់ព័ន្ធក្នុងស្រុក អង្គការផ្តល់ជំនួយទ្វេភាគី អាចចូលជាសមាជិកសង្កេតការណ៍ ហើយអាចចូលរួមប្រជុំតាមការអញ្ជើញរបស់ « ក.ជ.ក.ក » ។

**មាត្រា ៤** : « ក.ជ.ក.ក » មានភារកិច្ចដូចតទៅ ÷

- ជាស្ថាប័នថ្នាក់ជាតិ សំរាប់ការងារពិគ្រោះយោបល់ សំរបសំរួលសកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងបញ្ហាកុមារនៅក្នុងប្រទេសកម្ពុជា ។
- ជួយរាជរដ្ឋាភិបាលក្នុងការតាមដាន និងធ្វើរបាយការណ៍លើបញ្ហាទាំងឡាយដែលពាក់ព័ន្ធ នឹងកុមារជួយដូចជាអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ និង កម្មវិធីសកម្មភាពជាតិសំរាប់កុមារ ។
- ស្រាវជ្រាវ និងជូនពត៌មាន ស្តីពីសេចក្តីត្រូវការ និង បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងកុមារកម្ពុជាទៅរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការនានាដែលមានសមត្ថកិច្ច ។
- ទំនាក់ទំនងជាមួយសហគមន៍ជាតិ និងអន្តរជាតិដែលមានការងារប្រហាក់ប្រហែលគ្នា ដើម្បីប្តូរយោបល់បទពិសោធន៍ និងទស្សនៈរីកចំរើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការលើកលំអស្ថានភាពរបស់កុមារ ។

**មាត្រា ៥ :** « ក.ជ.ក.ក » មានរចនាសម្ព័ន្ធចាត់តាំង ដើម្បីដំណើរការដូចខាងក្រោម ៖

- មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ការិយាល័យមួយចំនួន សំរាប់បំពេញការងារដែលមានទីតាំងនៅក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ។
- អាចបង្កើតអនុគណៈកម្មការជំនាញ ដើម្បីធ្វើការងារមួយរយៈពេលតាមការកំណត ។
- មានគណៈកម្មការទីប្រឹក្សាមួយ ដែលមានសមាសភាពជាអ្នកជំនាញ ដើម្បីជួយ «ក.ជ.ក.ក» និងអគ្គលេខាធិការដ្ឋាន ។

**មាត្រា ៦ :** អគ្គលេខាធិការដ្ឋាន ប្រើប្រាស់បុគ្គលិកពីក្រសួងពាក់ព័ន្ធ ហើយចំនួនបុគ្គលិកកំណត់ដោយ «ក.ជ.ក.ក» ។

**មាត្រា ៧ :** តួនាទីភារកិច្ចរចនាសម្ព័ន្ធ និង ការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន ការិយាល័យអនុគណៈកម្មការ និង គណៈកម្មការទីប្រឹក្សាអាស្រ័យដោយ «ក.ជ.ក.ក» ជាអ្នកកំណត់សំរេច ។

**មាត្រា ៨ :** ថវិការបស់ «ក.ជ.ក.ក» ជាថវិកាមួយដោយឡែក ហើយជាឧបសម្ព័ន្ធថវិការបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ។

**មាត្រា ៩ :** «ក.ជ.ក.ក» មានបទបញ្ជាផ្ទៃក្នុង និង ត្រាមួយដោយឡែករបស់ខ្លួន ។

**មាត្រា១០ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១១ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងស្ថាប័នពាក់ព័ន្ធនានា ព្រមទាំង «ក.ជ.ក.ក» មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *